# កុមារដ្ឋាន

## រៀនអាន ហាត់សរសេរ



CA 6

ស ចិន្តា

# កុមារម្ហូប

# រៀនអាន ចាត់សរសេរ

Copyright by ANAKOTA
Imprimerie Paris
Achevé d'imprimé Mars 1977
Dépôt Légal Ier Trimestre 1977

ព.ស.២៥១៣ គ.ស.១៩៦៩

រក្សាសិទ្ធិ

លេខ-៦៦៣
ចុះថ្ងៃទី ២-៣-៦៦

# ប្រកាសក្រសួង

## ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងអប់រំជាតិ

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ។

បានឃើញព្រះរាជក្រឹត្យលេខ ៨៧០-ប ចុះថ្ងៃទី ២៥ ធ្នូ ឆ្នាំ១៩៦៥ កែប្រែដោយអត្ថបទក្រោយៗ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

បានឃើញព្រះរាជក្រឹត្យលេខ២៨៨-ប ចុះថ្ងៃទី៧ ឧសភា ឆ្នាំ ១៩៦៥ ស្ដីពីការតែងតាំងលោក សំរិទ្ធ-សុទ្ធ អនុរដ្ឋលេខាធិការ ក្រសួង អប់រំជាតិ ។

បានឃើញព្រះរាជក្រឹត្យលេខ ៣៨៧-ប ចុះថ្ងៃទី ២ កក្កដា ឆ្នាំ ១៩៦៥ ស្ដីពីការប្រគល់អំណាច ជូនលោក សំរិទ្ធ-សុទ្ធ អនុរដ្ឋលេខាធិការ ក្រសួងអប់រំជាតិ ចុះហត្ថលេខាលើប្រកាសក្រសួងនានាក្នុងក្រសួងអប់រំជាតិដែលមានលក្ខណៈជាបន្ទុកធម្មតា ។

បានឃើញប្រកាសក្រសួងលេខ ៣២៩២ ចុះថ្ងៃទី ១៦ កញ្ញា ឆ្នាំ ១៩៦១ ស្ដីពីការតែងតាំង គណៈកម្មការជាតិ ជ្រើសរើសសៀវភៅទី ១ សម្រាប់បឋមសិក្សាខ្មែរ ។

បានឃើញសេចក្ដីគំរោង ចុះថ្ងៃទី ៨ មករា ឆ្នាំ ១៩៦១ របស់គណៈកម្មការជាតិនេះ អប់រំជ្រើសរើសទី ១ សម្រាប់បឋមសិក្សាខ្មែរ ។

តាមការចាំបាច់នៃការអប់រំ ។

### សម្រេច ដូចមានសេចក្ដីខាងក្រោមនេះ:

**ប្រការ ១**–សៀវភៅដែលមានចំណងជើងថា **កុមារដ្ឋាន រៀនអាន - ហាត់សរសេរ** ដែលរៀបរៀងដោយលោក ស-ចិន្ដា ត្រូវបានដាក់ក្នុងចំណោមពួកសៀវភៅសិក្សា និងសៀវភៅខាងផ្នែកសិក្សា ដែលអនុញ្ញាតឱ្យប្រើប្រាស់គ្រប់សាលារៀនសាធារណៈ ក្នុងព្រះរាជាណាចក្រ ។

**ប្រការ ២** – នាយកខុទ្ទកាល័យ និងអគ្គនាយកនៃការអប់រំ ត្រូវទទួលភារៈ ចាត់ចែងតាមភារៈក្រសួងរៀងៗខ្លួន ដើម្បីឱ្យបានសម្រេចតាមប្រកាសក្រសួងនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២ មីនា ឆ្នាំ១៩៦៦

ជ- រដ្ឋមន្ត្រីក្រសួង អប់រំជាតិ

អនុរដ្ឋលេខាធិការក្រសួងអប់រំជាតិ

ហត្ថលេខា **សំរិទ្ធ-សុទ្ធ**

បានចម្លងតាមច្បាប់ដើម

ជ- អគ្គលេខាធិការ នៃគណៈរដ្ឋមន្ត្រី

ហត្ថលេខា : **ឧត្ត-ប៊ុនថន**

បានចម្លងត្រឹមត្រូវតាមដើម

អគ្គនាយកនៃការអប់រំ **ពុង-ប៉េង ចេង**

អ្នកទទួល :

- ទីស្ដីការព្រះរាជាបក្ខ
- ទីស្ដីការនាយករដ្ឋមន្ត្រី ។
- ទីអគ្គលេខាធិការដ្ឋាននៃគណៈរដ្ឋមន្ត្រី - ទីផ្សាយផ្ដល់ព័ត៌មាន ។
- រដ្ឋសភាជាតិ -ក្រុមប្រឹក្សាព្រះរាជាណាចក្រ ។
- ក្រសួងអប់រំជាតិ:ខុទ្ទកាល័យ -អនអ-អនបស-អនកត
- គ្រប់អធិការបឋមសិក្សា ក្នុងព្រះរាជាណាចក្រ ។
- សាមីខ្លួន ។
- ឯកសារ ។


១៩៦៦
៣
មីនា

សេចក្ដីកត់ហេតុ ចុះថ្ងៃទី ៤ មករា ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំមួយ នៅអធិការដ្ឋានបឋមសិក្សាក្រុងភ្នំពេញ គណៈកម្មការជាតិផ្ដែករងទី១ សម្រាប់បឋមសិក្សាខ្មែរ បានបើកសម័យប្រជុំក្រោមអធិបតីភាពលោក **ពុទ-ប៉េងចេង** ដើម្បីពិនិត្យជាលើកទី២ នូវសៀវភៅ **កុមារដ្ឋាន** **រៀនអាន ហាត់សរសេរ** និពន្ធដោយ **ស-ចិន្ដា**។

............................................................................................................

............................................................................................................

............................................................................................................

សៀវភៅ **កុមារដ្ឋាន** **រៀនអាន ហាត់សរសេរ** នេះ បានកែទំរង់ដោយយកចិត្តទុកដាក់តាមគន្លងនៃសេចក្ដីណែនាំរបស់គណៈកម្មការមានលក្ខណៈគ្រប់គ្រាន់ ល្មមចូលទៅក្នុងចំណោមពួក**សៀវភៅសិក្សាបាន** ។

**ប្រធាន**

**ពុទ-ប៉េងចេង**

**លេខាធិការ**

**លី-ឡាច**

សមាជិក

| | |
|---|---|
| ហួរ- ហេង | ផៃ - ផេង |
| គីម - ឈុំ | ណុប - ផុំ |
| ធី - សែម | បួរ - ខាំម៉ៅ |
| នីវ - អុល | អ្នកអង្គម្ចាស់ ស៊ីសុវត្ថិសុវណ្ណរេត |
| ឯក - អឿន | គីម យិន-ស៊ីសាមុត |

ក ខ គ ឃ ង

ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ

ត ថ ទ ធ ន

ប ផ ព ភ ម

យ រ ល វ ស

ហ ឡ អ ។

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ្ឡ អ្អ ា

អ អា អិ អី អឹ អឺ

អុ អូ អួ

អើ អឿ អៀ អេ

អែ អៃ អោ អៅ

អុំ អំ អាំ អះ ។

អុះ អេះ អោះ ។

ា ិ ី ឹ ឺ

ុ ូ ួ

ើ ឿ ៀ េ

ែ ៃ ោ ៅ

ុំ ំ ាំ ះ ៗ

ុះ េះ េាះ ៗ

# ក

ក កា កិ កី កឹ កឺ កុ កូ កួ កើ

កឿ កៀ កេ កែ កៃ កោ កៅ

កុំ កំ កាំ កះ ។ កុះ កេះ កោះ ។

## កកោះ

## កាកី

កី



# ត

ត តា តិ តី តឹ តឺ តុ តូ តួ តើ
តឿ តៀ តេ តែ តៃ តោ តៅ
តុំ តំ តាំ តះ ។ តុះ តេះ តោះ ។



# គ

គ គា គិ គី គឹ គឺ គុ គូ គួ គើ

គឿ គៀ គេ គែ គៃ គោ គៅ

គុំ គំ គាំ គះ ៗ គុះ គេះ គោះ ៗ

## គួងកោង គគីង



# ភ

ភ ភា ភិ ភី ភឹ ភឺ ភុ ភូ ភួ ភើ

ភឿ ភៀ ភេ ភែ ភៃ ភោ ភៅ

ភុំ ភំ ភាំ ភះ ៗ ភុះ ភេះ ភោះ ៗ

## កុំភវ គូវភេ



## សារឡើងវិញ

# កី ដី គី ភី

## កីកោះ ដីដួ គីគឺរ
## កីុំភីរ
## គីរហោ។



# ច ឆ

ច ចា ចិ ចី ចឹ ចឺ ចុ ចូ ចួ ចើ

ចឿ ចៀ ចេ ចែ ចៃ ចោ ចៅ

ចុំ ចំ ចាំ ចះ ។ ចុះ ចេះ ចោះ។

## ចំការ ចែចៅ ។

## ចៅភាចាំចំការ ។

## តាចូចេះចែចៅ។



# ឆ ធ

ឆ ឆា ឆិ ឆី ឆឹ ឆឺ ធុ ធូ
ធួ ធើ ធឿ ធៀ ធេ ធែ
ឆៃ ឆោ ឆៅ ធុំ ធំ ធាំ ធះ។
ឆុះ ឆេះ ឆោះ ។




## ឆាឆៅ គោធំ ។

## ចៅធឺឆាឆៅគេ ។

## ចែឆែភរចៅឆោ ។

សាឡើងវិញ

# ច ថ ឆ ធ

ចំការ ថែចៅ

ឆាអៅ គោធំ។



# ង ដ ជ ផ

ង ងា ដិ ដី ដឹ ដឺ ដុ ដូ ដួ ដើ

ដឿ ដៀ ដេ ដែ ដៃ ដោ ដៅ

ដុំ ដំ ដាំ ជះ ៗ ដុះ ផេះ ជោះ ៗ

## ការងារ ដុំដី កុំជឿ។

ការងារតាជូជុំដុំ ៗ

ដើ

គគីរដុះជាជួរ ៗ



# យ ឈ ឃ ស

យ យា យិ យី ឈឹ ឈឺ ឈុ ឈូ ឈួ ឈើ
សឿ សៀ សេ សែ សៃ ឃោ ឃៅ ឃុំ ឃំ
ឃាំ ឃះ ។ សុះ សេះ សោះ ។

## សេះឈរ ឃុំគគីរ កុំឃាំ។

តាឃុំឈរចាំ គេជិះ
ចៅសំ សេះស ។



សាឡើងវិញ

# ងពិពិផ ឃឈឃស

# ការងារ ពុំពឺ កុំជឿ

# ឃុំគឺគីរ សេះឈរ

# កុំយំ។



# ញ ណ ល ព

ញញួរ ដំណាំ សំណា ចំណី លលា

លាដៃ លាញី ពពែ ពុះពារ សំពះ ។

## ញញួរនេះធំ ។ ដំណាំដាំជាចំណី ។

## ពូសៅជិះលាញី ។

## ពពែឈរងីងើ ។



# ខ ទ ន ឡ

ខទា ខោស ខះក ទូឈើ ទីនេះ នគរ

នរណា ឡូឡា សំឡី លើឡៅ ។

## ទូឈើនៅលើឡៅ ។ ពូឡីចេះ
## ខទា ។ កុំឡូឡានៅទីនេះ ។
## ទាពីរនេះឈរ ។



សារឡើងវិញ

# ញ ណ ភ ល ប ព ខ ទ ឃ ឡ

ដំណាំដាំផាចំណភី ។ ទូឃើនៅ

លើឡេ ។ កុំឡូឡាទៅទិនេះ ។

ទាពីរនេះឈរ ។ ពពែឈរងើង ។



า ิ ี ึ ื

เ บ พ

อี อืใ อใ อ

อั อ้ อ า อ ๅ

ํ ํ ำ ะ ๅ

เ ่ ะ อ ะ อ า ะ ๅ

# ប ម ហ រ

បំពេ    បៅដោះ    មមើ    ហោរា

ហូរហែ    នារី    ខែរះ    វិហារ ។

វិហារ



ខែរះលើវិហារ ។ កុមារចេះ

បំពេ ។ ពពែបៅដោះមេវា ។

ធីតាចេះសរសេរហូរហែ ។

# ប្រជុំឡើងវិញ

ក តា គិ ភី ចី ចឺ ឆុ ធូ ងួ ដើ ជឿ ផៀ ឃេ
ឈែ យៃ សោ ពៅ ញុំ ណំ លាំ ពះ ។ ខុះ
ចេះ នោះ ។ ឡី បើ មេ ហែ រាំ វះ ។



## កុមារចេះគូរ



ពពែ




តោ ភេ



ញញួរ



សេះ



ដំរី



គោ



មូសិកទន្ត ឬ ធ្មេញកណ្ដុរ ' " '
វណ្ណយុត្តនេះសំរាប់ប្រើសម្លាប់បំបែរសម្លេង:

# ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

ង៉ាងុី ញុឹញុឺ ប៉ុប៉ូ ម៉ួមុើ រ៉េរ៉ែរ៉ៃ យ៉ោយ៉ៅ

យុំ ៗ រុះ រ៉េះ រ៉ោះ ៗ




វ៉ាលី ប៉ាឆា ចាបុី

ឆៃយុំ ៗ

កុមារចេះឆៃយុំ ៗ

តាម៉ៅលីចាបុី ៗ

គេទៅប៉ាឆា ៗ ជីកសំយំញ៉ែញ៉ ៗ ចៅ
វ៉ែលីវ៉ាលី ៗ ម៉ែចៅប៉ាប៉ះបោកប៉ៅខោ ៗ

ត្រីស័ព្ទ (៣)

វណ្ណយុត្តនេះសំរាប់ដាក់លើព្យញ្ជនៈមាន៤តួគឺៈ

# ៊

# បសហអ ប៊ស៊ហ៊អ៊

ប៊ា ប៊ិ ប៊ី ប៊ឹ ប៊ឺ ស៊ុ ស៊ូ ស៊ើ ហ៊ែ ហ៊ៃ ហ៊ោ

ហ៊ៅ ហ៊ុំ ហ៊ំ ។ អ៊ុះ អ៊េះ អ៊ោះ ។

## កៅស៊ូ តៅហ៊ូ

កៅស៊ូ



## ភាស៊ី សាប៊ូ ។

ជីតាតស៊ូទៅសាលា ។ ចៅប៊ីស៊ីតៅហ៊ូ ។ ពូប៊ូលើកៅស៊ូ ។ ពូជុំទៅទារភាស៊ី ។ សាប៊ូនៅលើតុ ។ កុមារឡូឡាហ៊ោទះដៃ ។

កក កាង កាយ

កាច កូន កើត

តប តាម តឹង

គយ គាញ គាយ

ភាយ ភូង ភោគ

រស្សសញ្ញា ឬ បន្តក '់'

វណ្ណយុត្តនេះសម្រាប់ស័រសម្លេងឲ្យកំបុតខ្លីនិងធ្ងន់៖

# ់

ភកកកក់ សងសង់ ចតចត់ ដបដប់ បន់ សល់

អស់ ចាកចាក់ កាចកាច់ បាញ់ ហាត់ ឆាប

ឆាប់ បាល់ ណាស់ ជក់ ទន់ ឈប់ យល់

ពស់ ទាត់ មាន់ រាល់ ទាស់ ។



## មេមាន់ តាចាស់

## ដប់ពីរ សង់សាលា។

## ជីតាចេះរាប់ដល់ដប់ ។

## កុំជក់បារី ។ បាល់

## កុមារហាត់ទាត់បាល់ ។ ចចកចាប់

## មេមាន់ ។ ពស់កាចណាស់ ។

# ក ត គ ភ

កប កាប កាយ កុន កូន កើត កង់ តង់

តាង តឹង តើន តែង តោង តាំង តក

គង គយ គិត គេង គុណ ភ័យ ភាយ

ភឿន ភៀស ភាំង ភូមិ ។

## តាំងតុ ភាន់ភាំង

## កូនចៅ

## គុណម៉ែ។



កាំរទេះ

ឪតាចេះពកូនង៉ា ។ គុណម៉ែ
ធំណាស់ ។ សរសេរកុំភាន់ភាំង ។
កុំតោងកាំរទេះគោ ។

# ច ថ ឆ ធ

ចប ចាន ចាយ ចុង ចូល ចេញ ចោម ចាំង
ចោទ ថយ ថើប ថែម ថោក ឆាក ឆាយ ឆើត
ឆែក ឆោត ឆាំង ធាង ធួន ធេង ។



## ចបកាប់ ធាងចេក
## ឆើតឆាយ
## ថើបកូន ។

ធាងចេកដុះសាខា ។ ពូចាន់លីចបទៅ
ចំការ ។ យាយឆោមថើបចៅគាត់ ។
ឆាកកុននេះឆើតឆាយណាស់ ។

# ង ដ ជ ផ

ងិត ងុយ ងើយ ង៉ែត ងាំង ដក ដាច់ ដឹង ដុស
ដូច ដួង ដើម ដែល ជាង ជាយ ជួន ជួប ជើង
ជៀស ផង ផាវ ផឹក ផុត ផើង ផែន ។

## ជើងមាំ ផើងដី កូនង៉ែត ។




កូនង៉ែត
នេះយំ ។
ដំរីស៊ីដើមចេក ។
ដើមដូងដុះជាជួរ ។
គោញីផើមពោះធំ ។

# ឃ ឈ យ ស

ឃាត់ ឃើញ ឃោស ឃាំង ឃាដ ឈប់ ឈាន
ឈឹង ឈុត ឈូស ឈោង យក យាន យ៉ាប់
យាយ យឹត យួន យើង យោគ សង់ សាច
សិន សុខ សួន សួង ស៊ើប សោម សាំង ។



ឈូសឈើ

ឃោសនាការ ។

ឈូសឈើ ។

យានជំនិះ ។

កសាងសាលា ។

កុមារទៅឃោសនាការ ។ ពូសានខំឈូសឈើ ។ ចៅសុខយកសេះជាជំនិះ ។ យើងឃើញយាយគង់ជូនចៅទៅសាលា ។

# ញ ណ ល ព

ញ៉ឹម ញាយ ញៀន ញាប់ ញឹក ញើស ញែក ញាតិ
ណាត ណាត់ ណឹង ណែភ ណែង លប លាង លុប
លុយ លើក លែង លេខ លេង លឿង លោក លោម
លោភ ពង ពិត ពឹង ពុត ពុក ពួន ពែង ពោត ពណ៌ ។

## ញាប់ញ័រ ពណ៌លឿង
## ពឹងពាង សាច់ញាតិ ។

កំណាត់នេះពណ៌លឿង ។

សត្វលាជាប់ចំណង ។

ពពែលួចស៊ីដំណាំ ។

ពូញ៉ឹមយកញញួរ

ទៅដំដែក ។



រណារ

# ខ ទ ន ឡ

ខាន ខឹង ខ្ទង់ ខ្សឿន ខែល ខោក ខែត្រ ទង

ទាន ទិស ទឹក ទុក ទូក ទួល ទើប ទោស ទាំង

នាង នាម និញ នឹម នុយ នូវ នួន នឿយ នែប

នោម ឡប់ ឡាន ឡើង ឡេវ ឡាំង ។

ឡឿនវិហារ ទូកង

ខែវះ ឡេវខោ

នឹមគោ កង់ឡាន ។



ឡានទំនិញ

ឡឿនវិហារនេះមាំណាស់ ។

ទូកងនេះលឿនដែរ ។ ឡានធំ

ដឹកទំនិញ ។ នឹមគោនេះសម ។

# ប ម ហ រ

បាប បិត បឹង បួន បើក បាំង មក មាន មុឺន
មុង មូស មួយ មើល មែន មោង ហិប ហួស
ហែក រាង រោម រាំង រង់ រិញ រេញ រែង
រាំង ហ្វូង ។

បឹងឈូក សត្វមូស រោមចៀម
ហិបដែក ចឹងឈូក
រាំរង ។



សត្វមូសបុនខាំ
មនុស្ស ។ បឹងនេះដុះឈូកស ។ពួយលីហិប
ឈើឡើងពីផែ ។ គេកាត់រោមចៀមយក
ទៅលក់ ។ បទរាំរង់នេះពីរោះណាស់ ។

## មេរៀនពិសេស

# កុមារនិងជីតារៀនប្រែកបចប់ហើយ



ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ្ឡ អ្អ ។

ក ខ គ ឃ ង

ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ

ត ថ ទ ធ ន

ប ផ ព ភ ម

យ រ ល វ ស

ហ ឡ អ ៗ

# ភាគសំរាប់គ្រូណែនាំសិស្ស

## វិធីផ្ញើព្យញ្ជនៈ ចែកជាពីរក្រុមៈ

១- ព្យញ្ជនៈ មានសម្លេងស្រាល អឃោសៈ ដូចជាៈ កខ, ចឆ, ជាដើម និងព្យញ្ជនៈ មានសម្លេងពីរ ដូចជាៈ ង-ង៉, ញ-ញ៉, ន-ន៉, ម-ម៉, ប-ប៉, យ-យ៉, រ-រ៉, វ-វ៉, ជាដើម ។ កាលបើយកជើងទៅផ្ញើព្យញ្ជនៈ ណា ត្រូវដួលសម្លេងទៅតាមព្យញ្ជនៈ លើទាំងអស់ ដូចពាក្យថាៈ ក្លូ ខ្ញុំ ខ្យ ជាដើម ។

២- ព្យញ្ជនៈ មានសម្លេងតែមួយ ដូចជាព្យញ្ជនៈ ជ ទ ព បើយកជើងទៅផ្ញើនឹងព្យញ្ជនៈ ណា ត្រូវសម្លេងព្យញ្ជនៈខាងលើដួលទៅតាមជើងព្យញ្ជនៈ ខាងក្រោមវិញ ដូចពាក្យថាៈ ខ្ជិឃ្នា, ខ្ទម, ខ្ពឹម ជាដើម ។

# ក្រ គ្រ ច្រ ជ្រ

ក្របី ក្រពើ ក្រសារ ក្រូចសើច ទីក្រុង គ្រួសារ
គប់គ្រង គ្រាន់បើ គ្រុនចាញ់ គ្រូពេទ្យ ច្រឡំ ច្រណែន
ច្រើនក្រៃ ជ្រលក់ ជ្រូកបា យប់ជ្រៅ ដើមជ្រៃ ខែជ្រៃ។



គ្រួសារកុមារ
ក្របី
នៅទីក្រុង ។
ច្រៀងបទ
រាំវង់ពេល
យប់ជ្រៅ ។

ខែជ្រៃដើមជ្រៃ មានជ្រូកច្រើន ។
ក្របីធំក្រៃ ចុះលេងទឹក ។

# ត្រ ទ្រ ប្រ ព្រ ស្រ ម្រ

ត្រកួល ត្រចៀក ត្រឹមត្រូវ ទ្រអ៊ូ ទ្រនំ
ទ្រុងជ្រូក ទ្រាំចាំ ប្រកប ប្រញាប់ ប្រាសាទ
កូនប្រុស ព្រមព្រៀង ព្រលឹង គោព្រៃ

គោព្រៃ



ស្រឡាញ់ កូនស្រី
ដើមស្រូវ ម្រាមដៃ
ដើមម្រេច
ម្រះព្រៅ ។

ត្រកួលត្រឹមត្រូវ ។ ទ្រអ៊ូតែមួយ
ពីរោះក្រៃ ។ កូនប្រុសចេះប្រកបការ ។
គោព្រៃមាននៅតែស្រុកយើង ។

# ក្ង ក្ដ ក្ន ក្ម ក្ល ក្ប ក្ស ក្អ

ក្ងានក្ងោក សត្វក្ដាន់ ក្ដោងទូក ក្នុងក្រៅ កូនក្មេង

ក្លាហាន ប្រទេសក្លិង្គ ក្បាលត្រី ក្បាច់ក្បូរ

ក្សេមក្សាន្ត ក្អមទឹក សត្វក្អែក ដុសក្អែល ។




សត្វក្ដាន់បោលភាំង

ក្ងោកភ័យ ។

ទូកក្ដោងដាក់ត្រី

សំដៅច្រាំង ។ សត្វក្អែកធំ

លើមាត់ក្អម ។ ក្ងានជាសត្វ

ស្រុករស់នៅក្សេមក្សាន្ត ។

# ខ្ច ខ្ញ ខ្ដ ខ្ន ខ្ម ខ្យ ខ្ល ខ្វ ខ្ស

ចេកខ្ចី ដើមខ្ចី ម៉ែខ្ញុំ មាន់ខ្ដត ខ្នាយជ្រូក
ខ្នើយកើយ ជាតិខ្មែរ ខ្មៅដៃ ខ្លាញ់ត្រី ខ្យងខ្ចៅ
ខ្វាក់ខ្វិន ដីខ្សាច់ ខ្សែក្រវាត់
ខ្សត់ខ្សោយ ។




ចេកខ្ចីជាចំណីចត់។
មាន់ខ្ញុំស្រែកខ្ដត
ជិតដើមខ្ចី ។
ខ្លាញ់ជ្រូកឆាត្រី
ជាអាហារ ។ ខ្ចៅនិងខ្យងរស់នៅ
ក្នុងបឹងដូចត្រីដែរ ។

# គ្ន គ្ម គ្ល ឃ្ន ឃ្ម ឃ្ល

គ្នាន់គ្នេរ គ្នាយើង គ្មានចំណោះ យង់ឃ្នង ឃ្នាបអំពៅ
ក្រាសឃ្មឹក ខ្មីឃ្មាត វាយឃ្មោះ ខ្លាឃ្មុំ ឃ្លាតឃ្លា
ឃ្លានបាយ ឃ្លុបទូក ឃ្លាលគោ ក្រូចឃ្លិច ។




ពួកយើងរាល់គ្នាខំខ្មីឃ្មាត ។
ត្រូវមានចំណេះកុំឃ្លៀងឃ្លាត ។
បើឃ្លានតោងខ្លាច
ដល់ពេលអត់ ។
ខ្លាឃ្មុំឈរ
ទំលើ
មែកឈើ ។

# ច្ន ច្ប ច្រ ឆ្ក ឆ្ង ឆ្ត ឆ្ន ឆ្ព ឆ្ល ឆ្ម ឆ្អ

ច្បាប់ស្រី សួនច្បារ ច្បុតចុះ ឆ្កាដៃ ឆ្កែឆ្កួត
ឆ្ងៀងឆ្ងល់ ត្រីឆ្តោ ត្រូវឆ្នោត ឆ្មាបា ឆ្មើងឆ្មៃ
ឆ្នាំឆ្លូវ ជើងឆ្វេង ស៊ីឆ្អែត ឆ្អឹងជំនីរ ។

មេអំបៅហើរលេងក្នុងសួនច្បារ។ ឆ្កែ
និងឆ្មាជាសត្វស្រុក ។ បើជួបនឹងចាស់
កុំឆ្មើងឆ្មៃ ។ ស៊ីឆ្អែត
បាត់ឃ្លាន
ដេកលក់
បាត់ខ្លាច ។



# ផ្ង ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ ញ្ហ

ចេកផ្ងា ឈ្ងោកមើល ឈ្នាន់កង់ ឈ្នួតក្បាល

មាន់ឈ្មោល ឈ្លក់ទឹក ឈ្មោះមនុស្ស

សត្វឈ្លូស ឈ្វេងយល់ ញ្ហើយចុះ ។



ឈ្លូស

ចេកផ្ងាច្រើនដុះនៅ មាត់កំពង់ ។ ធីតា ឈ្ងោកមុខហាត់ សរសេរ។លោកគ្រូស្រែកហៅចំឈ្មោះខ្ញុំ។ សត្វឈ្លូសស្រែកប៊ឺបតាមដងព្រៃ ។

# ថ្ក ថ្វ ថ្ន ថ្ម ថ្ល ថ្ង

# ត្ន ត្ប ត្ម ត្ល ត្អ

ដើមត្នោត កីត្បាញ មូលត្លុំ សត្វត្មាត ត្អូញត្អែរ ថ្កុំថ្កើង ថ្នាក់ថ្នម ថ្មកែវ ថ្វីដៃ ថ្ងៃត្រង់ ថ្លៃថ្នូរ ។




ទឹកត្នោតតក់ ៗ ពេញបំពង់ ។ សត្វត្មាតស៊ីខ្មោច ជាអាហារ។ បើចង់ថ្កុំថ្កើងត្រូវស្រឡាញ់ ការងារ។ រៀនសូត្រកុំត្អូញត្អែរទើបថ្លៃថ្នូរ។

# ទ្វ ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្វ

ក្លោងទ្វារ ទ្វេហារ ធ្ងន់ធ្ង បាញ់ធ្នូ ធ្មេញត្រី
ធ្យូងថ្ម ធ្លាក់ទឹក ធ្លុះ ធ្លាយ ធ្វើការ ធ្វេសប្រហែស។




កាលចាស់ជាន់មុន
ច្រើនប្រើធ្នូ ។
ធ្វើការកុំធ្វេស
ប្រហែស ។
ទ្វារនេះធ្លាក់ក្បាច់
យ៉ាងចំឡែក ។
ទឹកបឹងមើលធ្លុះ
ដល់បាតដី ។

# បបប ផផផផផផផ្រផ
# តលអ កតខឋងឆល បអ

ប្ដីប្រពន្ធ ដប់រៀលប្លាយ ផ្កាឈូក ចាប់ផ្ញើយ
ផ្សងផ្ដើម ផ្ដិលទឹក ផ្ញើជើង ផ្អត់ខោ ផ្អូរខ្វាច់



ផ្លាស់ប្ដូរ ផ្សារថ្មី ផ្លូវថ្នល់
នំផ្អម បងប្អូន ។
ខំរៀនផ្ញើជើង
តាមរបៀប ។
លោកគ្រូផ្ដែផ្ដាំ
សិស្សឲ្យចេះស្រឡាញ់គ្នា ។ កុំញ៉ាំនំ
ផ្អមនាំហើមពោះ ។ ប្ដីប្រពន្ធពីរ
នាក់នេះនាំគ្នាទៅផ្សារទិញត្រី ។

# ព្ន ព្យ ភ្ង ភ្ជ ភ្ញ ភ្ន ភ្ល

ផ្លែព្នៅ ព្យួរត្រី ព្យាង្គរាយ ព្យាយាម ភ្ងាទឿង ភ្ជួរស្រែ
ភ្ជុំបិណ្ឌ ភ្ញាក់ផ្អើល ភ្ញៀវស្រី ភ្នែកឆ្មា ភ្នំពេញ ភ្លឺច្បាស់
ភ្នក់ភ្លើង លេងភ្លេង គ្រាប់ភ្លៀង កូនភ្លោះ ។



ត្រូវចេះព្យាយាមហាត់សរសេរ ។

ភ្លៀងធ្លាក់ភ្ជួរស្រែឲ្យទាន់ពេល ។

ស្រីប្រុសក្មេងចាស់នាំគ្នាទៅបុណ្យភ្ជុំ ។

ក្រុងភ្នំពេញជាទីប្រជុំជន ។

# ម្ក ម្ខ ម្ង ម្ច ម្ជ ម្ញ ម្ដ ម្ន

ម្កាក់ ម្ខាង ម៉្ងៃ ម្ចាស់ផ្ទះ ម្ជុលដេរ
ម្ជូរក្រូច ម្ញិកម្ញ៉ក់ ម្ដាយខ្ញុំ ផ្លែម្នាស់ ។

ជីតាខ្ញុំគាត់ដាំដើមម្នាស់ពេញចំការ ។ ផ្លែជាសត្វចេះស្រែទ្យាញ៉ាម្ចាស់ ។ ម្ជូរក្រូចជ្រក់ត្រីមានរសជាតិណាស់ ។

ខ្ញុំលែងម្ញិកម្ញ៉ក់ដូចកាលពីតូចទៀតហើយ ។



# ម្ទ ម្ភ ម្យ ម្ល ម្ស ម្ហ ម្អ

ម្ទេសខ្មាំង ម្ភៃរៀល ម្យ៉ាងទៀត ម្លប់ជ្រៃ ម្លូព្រៃ
ឆ្នាំម្សាញ់ ម្សៅជ្រៃ ម្ហូបចំណី ដើមម្អម ។

ចំការម្លូនេះមានដាំដើមម្ទេសផង ។
គេយកម្សៅជ្រៃទៅធ្វើជាចំណី ។ គ្រួសារ
នេះបរិភោគម្ហូប
អាហារនៅក្រោមម្លប់ជ្រៃ
ដើមម្អមច្រើន
ដុះនៅ
វាលស្រែ ។



# លលលល្យលលលលល

# ខ្ គ ច្ ឃ្ ពុ ឲ ហ អ

មើលល្ខោន ល្ងង់ខ្លៅ ល្បីល្បាញ ផ្លែល្ពៅ

ដើមល្មុត ល្វាចេក ជាតិល្វីង ផ្លែល្ហុង

ខ្យល់ល្ហើយ សត្វល្អិត សៀវភៅល្អ ។

ល្ងង់ខ្លៅនាំអាប់ដល់ត្រកូល ។ មើល

ល្ខោនតោង




យល់ដល់សាច់

រឿង ។ ជាតិល្វីងជាជាងចិត្តមិនល្អ ។

សៀវភៅល្អរៀនឆាប់ចេះ ។

ម្ដាយកុមារដាំល្ពៅពេញចំការ ។

# ស្ក ស្ខ ស្ង ស្ដ ស្ថ ស្ន ស្ប ស្ម ស្យ ស្ល ស្វ ស្អ

ស្ករគ្រាប់ ស្ងប់ស្ងាត់ សើចស្ងាញ ដៃស្ដាំ

ស្នែងពពែ



ស្នែងក្របី ស្បែកគោ ស្មោះស្ម័គ្រ

ស្លាបព្រាប សត្វស្វា ស្អាតស្អំ ស្នឹងគោ

បើមិនចង់ឲ្យគោស៊ីស្រូវត្រូវ

ស្នែងគោព្រៃ



បោះស្នឹង ។ ដៃស្ដាំជាគូនឹងដៃ

ឆ្វេង ។ ស្វាឡើងដើមស្វាយ ។

កុមារចេះគូររូបស្នែង ។

ស្នែងគោ



ស្នែងក្របី



ស្នែងក្ដាន់



# ខ្ជ ខ្ទ ខ្ព ស្គ ស្ព

កុំខ្ជិល ខ្ជីខ្ជា ត្រីខ្ជឹង ខ្ជះខ្ជាយ ខ្ទេចខ្ទី ខ្ទឹមស ខ្ទមចាំចាប
ខ្ពង់ខ្ពស់ គួរខ្ពើម ខ្ពុរមាត់ ស្គាំស្គង ត្រីស្ពឹន ស្ពោះទៅទីណា។

ក្មេងខ្ជិលធ្វើការខ្ជីខ្ជា ។ បងស្រីខ្ញុំទិញបាន
ត្រីខ្ជឹងមួយ ។ ខ្ទមនេះបាក់បែកខ្ទេចខ្ទីអស់ ។
សិស្សណាខំរៀនចេះដឹងច្រើនបាន
ខ្ពង់ខ្ពស់ ។ ត្រីស្ពឹននេះហែលទឹករកចំណី ។
ខ្ញុំចេះគោរពចាស់ ទុំពុំដែលស្គាំស្គង ។



# ថ្គ ថ្ព ផ្គ ផ្ទ ស្គ ស្ទ ស្ព

ថ្គាមខ្លា ថ្ពាល់ត្រី ផ្គរលាន់ ផ្គត់ផ្គង់ ផ្ទាំងគំនូរ ផ្ទះខ្ញុំ
វាយស្គរ សស្គុះ ស្ទាបមើល ស្ទូងស្រូវ មើមស្ពៃ ។

## ជាងនេះឆ្លាក់ថ្គាមខ្លា

ធ្វើជារូបព្រះ។ ម្តាយខ្ញុំខំផ្គត់ផ្គង់ផ្ទុងផ្ដើមឱ្យរៀនសូត្រ។ ផ្ទាំងគំនូរនេះគេគូររូបផ្កាឈូក។
លោកគ្រូវាយស្គរប្រមូលសិស្សឱ្យចូលរៀន ។ ស្រីស្រុកស្រែចេះស្ទូងស្រូវ។ បងស្រីខ្ញុំកំពុងតែដកដើមស្ពៃ ។



# មេរៀនពិសេស



# ភាគសំរាប់គ្រូណែនាំសិស្ស

## ព្យាង្គតម្រួត

ព្យាង្គតម្រួតចែកជា ៦ ក្រុមគឺ :

១- ក្រុម "ក" គឺជើង ក ខ គ ឃ ត្រូវនៅបានតែក្រោមព្យញ្ជនៈ "ង" ដូចពាក្យថា:
ចង្កេះ , បង្ខំ , បង្គី , សង្ឃឹម . . . . . ជាដើម ។

២ - ក្រុម "ច" គឺជើង ច ឆ ជ ឈ ត្រូវ . "ញ" ដូចពាក្យថា:
កញ្ចក់ , កញ្ជក់ , បញ្ជី , បញ្ឈប់ . . . ជាដើម ។

៣- ក្រុម "ដ" គឺជើង ដ ឋ ឌ ឍ ត្រូវ . . "ណ" ដូចពាក្យថា:
កណ្ដាប , សណ្ឋាន , ជាដើម. ជើង ឌ ឍ មិនសូវមានប្រើទេ

៤. ក្រុម "ត" គឺជើង ត ថ ទ ធ ត្រូវ . . . "ន" ដូចពាក្យថា:
បន្ទុក . បន្ថយ , កន្ទេល . កន្ធាយ ជាដើម ។

៥- ក្រុម "ប គឺជើង ប ផ ព ភ ត្រូវ . . "ម" ដូចពាក្យថា:
ដើម្បី , បុប្ផា , គម្ពីរ , ស្គរសម្ភោ ជាដើម ។

៦- ព្យញ្ជនៈ គ្មានក្រុមគឺ : ជើង យ រ ល វ ស ហ អ
នៅក្រោមព្យញ្ជនៈណាក៏បាន ដូចពាក្យថា:
ពន្យល់ , កម្រែ , ផ្ទៃទម្លាប់ , អង្ករ , សង្ស័យ , ទន្សាយ
សង្ហា , ចង្អេរ , ជាដើម ។

## ព្យាង្គតម្រួត (គ)

កង្កែប ចង្កេះ ចង្កា ចង្កូត ចង្កៀង ដង្កូវ ដង្កៀប
បង្កង បង្កើត សង្កាត់ សង្កត់ សង្កែ សង្កើច អង្ករ
អង្កាម អង្កៀម បង្ខំ សង្ខេប សង្ខារ គីង្គក់ បង្គី
បង្គន់ អង្គរ សង្ឃឹម ។


គីង្គក់

កង្កែបកបៗ ក្នុង
ដង្កៀបត្រែង ។
ដង្កូវវារលើ
ស្លឹកសង្កែ ។ យកបង្គីទៅកើប
អង្កាមនៅក្បែរបង្គន់ ។ គីង្គក់
លោតផ្លោតចាប់មេភ្លៀង ។

# ព្យាង្គតម្រួត (ត)

កញ្ជ្រោង កញ្ច្រាំង កញ្ច្រែង កន្ត្រៃ តន្ត្រី មន្ត្រី អង្រែត
អង្រឹង អង្រែ ពង្រូល ចង្រិត បង្រៀន ពុទ្រា
ទន្សោង ទន្សាយ សន្សើម កន្សែង សន្សំ កប្បាស
ដើម្បី សម្បត្តិ សុប្បី សន្យា មធ្យម ។

កញ្ជ្រោងឃើញទន្សោងបែបចង់ភ័យ ។

ជីតាបង្រៀនប្អូនក្នុងអង្រឹងថា ក.ខ ។

ចង្រិតយំច្រែកនៅ គុម្ពកប្បាស ។



# ព្យាង្គតម្រួត (ត)

កញ្ចាញ់ចេក បញ្ចូល កញ្ចក់ បញ្ចប់ បញ្ចុះ បញ្ចុក
កញ្ជោង កញ្ជក់ បញ្ជី អញ្ជើញ បញ្ឈប់ កញ្ញា
សញ្ញា កណ្ដុរ កណ្ដៀវ កណ្ដឹង កណ្ដូប កណ្ដៀរ
អណ្ដើក អណ្ដូង បន្តក់ បន្ថយ បន្ថែម កន្ធាយ
កម្ពុជា គម្ពីរ ប៉ុន្មាន ទូន្មាន ។




ម្ដាយកុមារបានទូន្មានកូនឲ្យ
ចេះអត់ទ្រាំ ។

ទន្សាយនិងអណ្ដើកតែងមានការទាក់ទងគ្នា ។ កញ្ចាញ់ចេកលោតលើមាត់អណ្ដូង ។ កណ្ដៀរចេះពូនដីដាលំនៅ ។

## ព្យាង្គតម្រួត (ត)

មន្ទីរ មន្ទិល បន្ទាយ ទន្ទឹង អន្ទាក់ រន្ទះ កន្លង
គន្លង កន្លែង ទន្លេសាប រង្វាន់ រង្វង់ ចង្វាក់
វង្វេង សង្វេគ បង្ហាត់ ដង្ហក់ បង្ហាញ បង្ហូរ
បង្អន់ បង្អែម បង្អួត ចង្អេរ ។

យើងត្រូវបង្ហាត់ឆ្កែឲ្យចេះចាប់កណ្ដុរកុំឲ្យវាស៊ីស្រូវ ។ ទន្លេសាបមានត្រីគ្រប់មុខ ។ សិស្សណារៀនពូកែត្រូវបានរង្វាន់ ។ ជីតាទន្ទឹងមើលផ្លូវម្ដាយមកពីផ្សារ ។



# ប្រជុំឡើងវិញ


កន្ទុំរុយ
ដង្កូវ
កណ្ដូបសេះ
ពង្រូល
កញ្ជ្រាញ់ចេក
ចង្រិត
ទន្សោង
កញ្ជ្រោង
ទន្សាយ
អណ្ដើក
កណ្ដុរ
គីង្កក់
កង្កែប
ត្រី
បង្កង

# អអាឥឦឧឩឫឬឭឯឰឱឳ

ឪពុក ឪឡឹក សត្វឩឡ ឦសាន ឧត្តម ឧកញ៉ា
ឯកឯង ឫស្សី ឱកាស ឮទេ ឬនៅ ក្រឱឈ្ងូក
ឰដ៏ ឥឡូវ រឭក ឫកពា ។

ឪពុកកុមារបាចស្រូវឱ្យមាន់ស៊ី ។ ខ្យល់បក់ពីទិសឦសាន ។ ឮស្នូរសម្លេងឯកខ្លែងនៅឰដ៏អាកាស។ ឥឡូវម្ដាយផ្ញើតាចុះទៅដកក្រឱឈ្ងូកតែម្នាក់ឯង



# ការធ្វើដំណើរ



ឪពុកកុមារតែងធ្វើដំណើរទៅខេត្តបាត់ដំបង ជាញឹកញាយណាស់ ជួនកាលគាត់ជិះរថយន្ត និងជួនកាលទៀត



គាត់ជិះរថភ្លើង ។ ការធ្វើដំណើរបែបនេះ អាចឲ្យគាត់ បានស្គាល់ភូមិនិងស្រុកទាំងឡាយ ។



ចំណែកម្ដាយកុមារវិញ ស្រុកកំណើតរបស់គាត់នៅខេត្តកំពង់ចាម ។



ពេលបុណ្យភ្ជុំម្ដងៗ គ្រួសារកុមារ បានធ្វើដំណើរតាមជើងទឹក គឺជិះកប៉ាល់ ។ ការធ្វើដំណើរតាមជើងទឹក គេតែងឃើញទូកជាច្រើន ទូកខ្លះបើកក្ដោង ទូកខ្លះចែវ ឯទូកតូចៗ គេអុំនិងច្រវា ។



បើធ្វើដំណើរតាមអាកាស ត្រូវជិះយន្តហោះ ។

# បុណ្យចូលឆ្នាំ

នៅពេលបុណ្យចូលឆ្នាំ  កុមារនិងធីតាក៏បានទៅលេងស្រុកកំណើតរបស់ម្ដាយឪពុកខ្លួន  ដូចជាកុមារាកុមារីឯទៀតដែរ ។ ជីដូននិងជីតាធីតា  គាត់ទាំងពីរជាចាស់ទុំបានទៅធ្វើបុណ្យនៅឯវត្ត  តាមប្រពៃណីរបស់ខ្មែរយើង ។

ចំណែកម្ដាយនិងឪពុកកុមារ  គាត់បានដើរកំសាន្តលេងក្នុងភូមិ  ដើម្បីរាប់រកញាតិសន្តានដែលយូរ ៗ ជួបគ្នាម្ដង ។

បើកំឡោះនិងក្រមុំវិញ  គេនាំគ្នាលេងល្បែងចោលឈូងនិងបោះអង្គុញនៅទីធ្លាយ៉ាង  សប្បាយ ។

ឯកុមារានិងកុមារីតូច ៗ  ប្រជុំគ្នា  លេងយ៉ាងរីករាយតាមតែចិត្តចង់ ។



# កុមារនិងធីតាទៅសាលារៀន

កុមារនិងធីតាបានបណ្ដើរគ្នាទៅសាលារៀនជារៀងរាល់ថ្ងៃ ពេលទៅសាលាឬចេញពីសាលា កុមារតែងតែនាំធីតាមិនឲ្យប្រទៀងគ្នាលេងតាមផ្លូវឡើយ ។

មុននឹងដើរឆ្លងថ្នល់ កុមារនិងធីតាបានកាន់ដៃគ្នាជាប់ហើយងាកមើលឆ្វេងស្ដាំយ៉ាងម៉ត់ចត់ កាលបើឃើញថាគ្មានអ្វីបរកាត់ទេ ទើបហ៊ានដើរឆ្លងទៅ ។

ការប្រយ័ត្នបែបនេះ កុមារនិងធីតាពុំដែលមានគ្រោះថ្នាក់សោះ ។



# ចំការឪឡឹក

ថ្ងៃអាទិត្យនិងថ្ងៃព្រហស្បតិ៍ ជាថ្ងៃកុមារនិងធីតាបានឈប់សម្រាក ។ នៅពេលឈប់សម្រាកនេះ កុមារនិងធីតាវាមិនរត់លេងឥតប្រយោជន៍ទេ ។ វាទាំងពីរនាក់ត្រូវទៅជួយធ្វើការឪពុកម្ដាយនៅឯចំការឪឡឹក ។

កុមារខំដកស្មៅតាមគន្លងឪឡឹកយ៉ាងញាប់ដៃ ។ ធីតាក៏ធ្វើការដូចជាបងរបស់វាដែរ ។ រីឯឪពុកកុមារគាត់ជាអ្នកជំរះស្មៅនិងជីកដីយកទៅពូនគុម្ពឪឡឹក ។ ចំណែកម្ដាយកុមារវិញ គាត់ដើរមើលថែទាំក្នុងចំការដើម្បីសម្លាប់ដង្កូវកុំឲ្យវាស៊ីត្រួយឪឡឹក ។



# រុយរោមចំណី

កុមារជាក្មេងចេះដឹងណាស់ កាលណាម្ដាយវាប្រដៅពីរឿងអ្វីមួយ វានៅចាំជានិច្ច ។ បើវាឃើញសិស្សតូចៗណាធ្វើខុស វាក៏រំលឹកភ្លាម ។ មានមួយថ្ងៃ វាឃើញសិស្សរួមថ្នាក់ជាមួយម្នាក់ ចេះតែរត់ទៅទិញចំណីមិនស្អាតមកញុំា វាក៏ប្រាប់ភ្លាមថា៖ ឯងកុំញុំាចំណីមិនស្អាតអីចឹង! ព្រោះចំណីណាដាក់ចោលរុយវាតែងមករោម ។

បើរុយរោមហើយ យើងញុំាទៅមុខជាឈឺពោះ ឬនាំឲ្យយើងមានជម្ងឺផ្សេងៗទៀតផង ។



ឯងមើលន៍! រុយវារោមធុងសម្រាមអីចឹង! មេរោគអាក្រក់តែងតែជាប់នៅនឹងជើងវាជាមិនខាន ។

ការណែនាំយ៉ាងនេះ រអាចឲ្យកុមារាកុមារីទាំងឡាយយល់ច្បាស់នូវវិធីអនាម័យ ។

# ម្រាមដៃជាមិត្តរបស់យើង

ចៅសុខនិងកុមារជាសិស្សរៀននៅក្នុងថ្នាក់កុមារដ្ឋានដូចគ្នា ។ ពេលចេញពីសាលារៀន ចៅសុខបានចូលទៅលេងផ្ទះកុមារ ។

ចៅសុខឃើញតុសរសេររបស់កុមារស្អាតឡើងរលោង ហើយនិងប្រដាប់ប្រដារៀបចំមានរបៀបក៏សួរថាៈ យី! តុរបស់ឯងស្អាតណាស់ ហើយប្រដាប់ប្រដាក៏រៀបចំល្អដែរ តើឯងមានពេលឯណានឹងធ្វើ បើមកពីសាលាវិញ ឃើញតែជួយធ្វើការឪពុកម្តាយគ្មានទំនេរសោះអីចឹងនោះ?។



កុមារព្រឺចៅសុខសួរបែបឆ្ងល់យ៉ាងនេះ ក៏ញញឹមហើយឆ្លើយថាៈ អូ!.ឯងកុំឆ្ងល់ធ្វើអ្វី ឯងមើលនែ យើងមានសំឡាញ់ដប់នាក់ឃើញទេ? ចៅសុខឃើញកុមារលើកម្រាមដៃទាំងដប់មកបង្ហាញខ្លួន ក៏សើចហាស!.ហាស!.. ហើយនិយាយថាៈ ចាប់តាំងពីថ្ងៃនេះតទៅ យើងនឹងខំយកតម្រាប់តាមកុមារឯងទាំងអស់ ។

# កណ្ដុរជាសត្វចង្រៃ

សត្វកណ្ដុរវាដើររកចំណីស៊ីតែវេលាយប់ ។ ឆ្មាពុំទាន់ឃើញនៅពេលថ្ងៃ វាចេញទាំងស្រួចហើយមុត អាចកកេររបស់រឹងបាន ។ វានៅបានតែកន្លែងណាកៀនកោះប្អូកកាយរូងនៅក្នុងដី ។

កណ្ដុរវារពិសមាត់ណាស់ ទោះបីរបស់ដែលវាមិនត្រូវការស៊ីក៏ដោយ ក៏វាកកេរលេងជាល្បែងដែរ ។



កាលណាយើងដេកលក់អស់ វាក៏ចេញមករកស៊ី ប្រសេចប្រសាចត្រប់ច្រកល្ហក ។ បើយើងមិនចង់ឲ្យមានសត្វកណ្ដុរទេ ត្រូវតែដាក់អន្ទុបនិងរោយថ្នាំបំពុល ឬចិញ្ចឹមឆ្មា ព្រោះឆ្មាវាត្រូវការសាច់កណ្ដុរជាអាហារ ។

# កញ្ជ្រោងនិងចចកជួបអណ្ដើក

កញ្ជ្រោងនិងចចកបានដើររកស៊ីក្នុងព្រៃជាមួយគ្នា ។ មានមួយថ្ងៃ សត្វទាំងពីរបានជួបនឹងអណ្ដើកមួយកំពុងតែវារតើមៗតែម្នាក់ឯង ចចកក៏ស្ទុះទៅសង្កត់ក្បាលអណ្ដើកជាប់ ចំណែកកញ្ជ្រោងយកជើងទាំងពីរទៅសង្កត់លើស្នូកអណ្ដើកដែរ ។ អណ្ដើកភ័យផងខំដកកផង ហើយនិយាយថា: ម្ដេចក៏បងកញ្ជ្រោងនិងបងចចកមកធ្វើបាបខ្ញុំអីចឹង ? កញ្ជ្រោងសើចមើលមុខចចកហើយតបថា:

យី!..ម្ដេចក៏ឯងសួរយើងធ្វើពីរអីចឹង ? ឯងមិនដឹងថាយើងត្រូវការស៊ីសាច់របស់ឯងទេឬ ? ចចកធ្វើឫកសង្ហាប្រាប់ទៅកញ្ជ្រោងថា: បើយើង ចង់ស៊ីសាច់



អណ្ដើក ទាល់តែយកដុំថ្មមកដំស្នូកវាឲ្យបែកសិន ព្រោះស្នូកវារឹងណាស់ ។ អណ្ដើកឮកញ្ជ្រោងថា ចង់យកដុំថ្មមកដំខ្លួនក៏ភ័យណាស់ ។ ប៉ុន្ដែខំនិយាយយ៉ាងក្លាហានថា: អូ!..បងឯងគិតយកថ្មមកដំស្នូករបស់ខ្ញុំឬ ? អត់ប្រយោជន៍ទេបងអើយ ! ទោះបីបងឯងទាំងពីរនាក់ទៅជញ្ជូនថ្មឲ្យអស់ពីភ្នំ ក៏ដំស្នូកខ្ញុំមិនបែកដែរ

# កញ្ជ្រោងនិងចចកសែងអណ្ដើក

ចចកឮអណ្ដើកថាដំនឹងថ្មមិនបែក ក៏ប្រាប់ទៅកញ្ជ្រោងថាៈ បើដំនឹងថ្មមិនបែកទេ យើងត្រូវគរភ្លើងដុតវា ។ អណ្ដើកឮថាគេគិតយកខ្លួនទៅដុតនឹងភ្លើងក៏រិតតែភ័យខ្លាំងឡើង ។ ប៉ុន្តែខំប្រឹងសើចហាស!.. ហាស!..ថា ៖

បើបងឯងយកទៅដុតនឹងភ្លើង ខ្ញុំសូមអរគុណនឹងបងឯងច្រើនណាស់ ព្រោះខ្ញុំនិងភ្លើងដូចជាទឹកនិងត្រីដែរ ។ បើបងឯងមិនជឿទេ សូមបងទាំងពីរនាំគ្នាទៅជញ្ជូនឧសឲ្យបានច្រើនមកដុតចុះ ចាំខ្ញុំដើរលេងក្នុងភ្លើងឲ្យបង មើលម្ដង ។



កញ្ជ្រោងកាលបើយល់ថា ប្រើភ្លើងនិងថ្មមិនបានការ ក៏ប្រាប់ទៅចចកថាៈ

យើងត្រូវយកវាទៅចោលក្នុងទឹកវិញ តើវាពូកែយ៉ាងដូចម្ដេចទៀត? ។

អណ្ដើកអរណាស់ ព្រោះគេថាយកខ្លួនទៅចោលក្នុងទឹក ប៉ុន្តែធ្វើជាភ័យរញ្ជីររញ្ជ័រថាៈ សូមបងទាំងពីរមេត្តាកុំយកខ្ញុំទៅចោលក្នុងទឹក ស្លាប់ខ្ញុំហើយ ។ កញ្ជ្រោងឃើញអណ្ដើកភ័យក៏សើច ហាស!. ហាស!. ថាៈ អញរកតែឲ្យឯងស្លាប់ហ្នឹងហើយ! ។ វានិយាយរួច ក៏នាំគ្នាសែងអណ្ដើកទៅគ្រវាត់ចោលក្នុងបឹងតែម្ដង ។

# ទឹកជាស្រុកកំណើតរបស់អណ្ដើក

អណ្ដើកលិចបាត់មួយសន្ទុះ ទើបអើតក្បាលចេញពីក្នុងទឹកមកវិញ រួចស្រែកប្រាប់ទៅកញ្ជ្រោងនិងចចកថាៈ

អើ!...បងភ្លើទាំងពីរ ខ្ញុំសូមអរគុណានឹងបងឯងច្រើនណាស់ ព្រោះទឹកជាស្រុកកំណើតរបស់ខ្ញុំដឹងទេ ? ។

ពេលនេះកញ្ជ្រោងនិងចចកទើបដឹងថាចាញ់បោកអណ្ដើក ហើយមើលមុខគ្នាភ្លឹះ ៗ ដោយអស់សង្ឃឹម ។

ចំណែកអណ្ដើកវិញ វាសប្បាយចិត្តណាស់ ព្រោះត្រូវបានចាកផុតពីគ្រោះថ្នាក់ ដោយបញ្ញាឈ្លាសវៃរបស់ខ្លួន ។



# ក្រូចពីរកំប្រោង

កុមារនិងចៅសុខមានអាយុដំណាលគ្នា បានយួរក្រូចម្នាក់មួយកំប្រោងមកពីចំការ ។ ដើរមកដល់ពាក់កណ្ដាលផ្លូវ ចៅសុខផ្ងើមុខជូរហើយត្អូញថា: ឈប់សិនកុមារគ្នាអោយដៃ



ណាស់ ឯងម្ដេចក៏ធ្វើព្រងើយអ៊ីចឹង? ចំណែកកុមារដែលមិនចេះត្អូញត្អែរនិងការនឿយហត់ បានឆ្លើយទាំងញញឹមថា: សុខអើយខ្ញុំក៏អោយដៃដូចឯងដែរ ប៉ុន្តែការខំប្រឹងតស៊ូ គឺការព្យាយាម ដែលជាហេតុនាំឲ្យបំភ្លេចការនឿយហត់បន្តិចបន្តួចនេះបាន ។ ចៅសុខឮពាក្យព្យាយាមភ្លាម ក៏មើលមុខកុមារហើយសើចយ៉ាងក្អាកក្អាយ ។ បន្ទាប់មកកុមារនិងចៅសុខបាននាំគ្នាចាប់យួរកំប្រោងក្រូចធ្វើដំណើរទៅមុខទៀត ។

# ខ្លាចង់ស៊ីសាច់ស្វា

បើគេចិញ្ចឹមខ្លាតោងធ្វើទ្រុងដាក់វា ព្រោះខ្លាជាសត្វកាចសាហាវណាស់ ។

មានមួយពេល សត្វខ្លាបានឃើញស្វាដើរមកជិតទ្រុងរបស់ខ្លួន វាក៏ស្រែកអង្វរសត្វស្វាថា:



សូមបងស្វាមេត្តាជួយដកគន្លឹះទ្វារទ្រុងនេះឲ្យខ្ញុំផង បើបងជួយខ្ញុំបាន ខ្ញុំនឹងមិនភ្លេចគុណបងអស់មួយជីវិត ។

ស្វាអាណិតពាក្យអង្វរករបស់សត្វខ្លា ក៏ដើរសសៀរចូលទៅទាញគន្លឹះទ្វារ ។ ខ្លាបានរួចពីទ្រុងហើយ វាក៏និយាយបែបកាចសាហាវទៅកាន់ស្វាថា: ឥឡូវនេះខ្ញុំចង់ស៊ីសាច់បងស្វាឯងណាស់ ព្រោះខានស៊ីសាច់ស្រស់យូរហើយ ។

# សុភាទន្សាយ

ស្វាឮខ្លាថាចង់ស៊ីសាច់ខ្លួន ក៏និយាយដោយភ័យញ័រថាៈ ឃើញម្ដេចក៏បងខ្លាឯងចង់ស៊ីសាច់ខ្ញុំទៅវិញ ព្រោះខ្ញុំជាអ្នកជួយបងឯងឲ្យរួចពីទ្រុងដឹងទេ ? ។

ខ្លាមើលមុខស្វាភ្លៀក ៗ បំរុងនឹងសង្គ្រុប ហើយនិយាយខ្លាំង ៗ ថាៈ

អញដឹងហើយ !.. មិនបាច់ឯងនិយាយប្រាប់អញទៀតទេ ។

ពេលនោះបងទន្សាយដែលកំពុងតែអង្គុយលើគល់ឈើបានស្រែកសួរទៅខ្លានិងស្វាថាៈ

អើបងខ្លានិងបងស្វាទាស់ទែងគ្នាពីរឿងអ្វីហ្នឹង ? នាំគ្នាមកឯណេះមើល ខ្ញុំកាត់ក្ដីឲ្យ ។ ស្វានិងខ្លាកាលបើឮដូចនេះភ្លាម ក៏នាំគ្នាទៅឈរពីមុខទន្សាយ រួចស្វានិយាយដោយរួសរាន់ថាៈ



សូមបងទន្សាយជួយគិតមើល ខ្ញុំជាអ្នកជួយគាត់ឲ្យរួចពីទ្រុង គាត់បែរជាចង់ស៊ីសាច់ខ្ញុំទៅវិញ ខ្ញុំមិនសុខចិត្តទេ ។

# ខ្លាចូលទ្រុងវិញ

ខ្លាបានឆ្លើយតាំងទឹងទៅវិញថា៖ យើងមិនបានគិតពីរឿងជួយមិនជួយនោះទេ ព្រោះតែឡូវនេះយើងឃ្លានណាស់ ។ ទន្សាយយល់ថា ខ្លាជាសត្វសាហាវក៏ធ្វើជានិយាយសំឡុតស្វាថា៖ បងស្វាឯងសមតែបងខ្លាស៊ីអីចឹងហើយ! ប៉ុន្តែខ្ញុំចង់ដឹងរឿងពិតពីដំបូងឡើងសិន តើយ៉ាងដូចម្ដេចទៅ ? ។

ខ្លាដោយចង់ស៊ីសាច់ស្វាពេក ក៏ធ្វើឲ្យទន្សាយមើល ។

ខ្លាចូលទៅដល់ក្នុងទ្រុងវិញ ស្វាក៏ស៊កគន្លឹះដូចដើម ហើយបំរុងដកគន្លឹះចេញមកវិញ ។ ពេលនោះ ទន្សាយស្ទុះទៅទាញដៃស្វាចេញមិនឲ្យដកគន្លឹះ រួចបន្ទោសស្វាថា៖ ឃើអើ!.. បងស្វាឯងមិនស្គាល់ស្លាប់ទេឬ ? យើងទុកឲ្យអាសត្វល្មើសគុណានេះ រស់នៅក្នុងទ្រុងអស់មួយជីវិតចុះ ។



# កុមារចេះសរសេរសំបុត្រ

ភ្នំពេញ នៅថ្ងៃទី ២ ខែ មីនា ឆ្នាំ ១៩៦៦



សូមជំរាបមកលោកតានិងលោកយាយទាំងពីរជាទីគោរព ។

កាលចៅមិនទាន់បានចូលសាលារៀននៅឡើយ ចៅតែងតែនឹកខ្លាចសាលានិងខ្លាចរំពាត់របស់លោកគ្រូជានិច្ច ។

ប៉ុន្តែការនឹកស្មាននោះខុសទេ ព្រោះលោកគ្រូក្នុងថ្នាក់របស់ចៅគាត់ខំព្យាយាមបង្រៀនកូនសិស្សណាស់ គាត់តែងតែប្រើសំដីល្មួងលោមសិស្សឲ្យចេះខំរៀនសូត្រ ។ ហេតុនេះហើយបានជាចៅប្រឡងឡើងថ្នាក់មិនពិបាកសោះ ។

នៅពេលវិស្សមកាលនេះ ចៅច្បាស់ជាមកលេងជាមួយលោកតានិងលោកយាយជាមិនខាន ហើយចៅនឹងរកសៀវភៅណាល្អៗ មករៀនអានផង ដើម្បីកុំឲ្យពេលវេលាកន្លងហួសទៅដោយឥតប្រយោជន៍ ។

គួរពុំគួរសូមលោកតានិងលោកយាយអភ័យទោស .

ហត្ថលេខា

កុមារ

# ខ្យល់ជំនោរ

ជំនោររំភើយ   បោកបក់រហើយ   បក់ដល់គុម្ពស្មៅ
ស្មៅដុះពេញដី   ជំនោរបក់ទៅ   បក់ប៉ះកួនស្មៅ
ស្រស់ដូចសំណាប ។

ជំនោរត្រជាក់   បក់មកគ្មានអាក់   បក់សំបុកចាប
ចាបភ្ញាក់ឡើងហើយ   ក្រោកទទះស្លាប   បក់ដាស់កូនចាប
ស្រែកច្រៀងខ្សៀវខ្សា ។

ជំនោរផាយផាត់   បក់បោករសាត់   បក់ដល់គុម្ពផ្កា
ផ្កាដុះរបាង   រីកពេញសួនច្បារ   ខ្យល់បក់ទងផ្កា
ររាំសប្បាយ ។

ជំនោររំភើយ   ថ្ងៃរះឡើងហើយ   កុមាររីករាយ
ភ្ញាក់ពីដំណេក   សំអាតរូបកាយ
លាឪពុកម្ដាយ   ទៅសាលារៀន ។



អត្ថបទបន្ថែមដោយៈ ឯក-អឿន

# លេខរៀងពី១ដល់១០០

១_២_៣_៤_៥_៦_៧_៨ ៩ ១០

១១_១២_១៣_១៤_១៥_១៦_១៧_១៨_១៩_២០

២១_២២_២៣_២៤_២៥_២៦_២៧_២៨_២៩_៣០

៣១_៣២_៣៣_៣៤_៣៥_៣៦_៣៧_៣៨_៣៩_៤០

៤១_៤២_៤៣_៤៤_៤៥ _៤៦_៤៧_៤៨_៤៩_៥០

៥១_៥២_៥៣_៥៤_៥៥_៥៦_៥៧_៥៨_៥៩_៦០

៦១_៦២_៦៣_៦៤_៦៥_៦៦_៦៧_៦៨_៦៩_៧០

៧១_៧២_៧៣_៧៤_៧៥_៧៦_៧៧_៧៨_៧៩_៨០

៨១_៨២_៨៣_៨៤_៨៥ ៨៦_៨៧_៨៨_៨៩_៩០

៩១_៩២_៩៣_៩៤_៩៥_៩៦_៩៧_៩៨_៩៩

១០០

១_អាទិត្យ ២_ចន្ទ ៣_អង្គារ ៤_ពុធ

៥_ព្រហស្បតិ៍ ៦_សុក្រ ៧_សៅរ៍

# ចន្ទគតិ

១

១_ មិគសិរ ២_ បុស្ស ៣_ មាឃ

៤_ ផល្គុន ៥_ ចេត្រ ៦_ ពិសាខ

៧_ ជេស្ឋ ៨ អាសាធ ៩_ ស្រាពណ៍

១០_ ភទ្របទ ១១_ អស្សុជ ១២_ កត្តិក ។

# សុរិយគតិ

១_ មករា ២_ កុម្ភៈ ៣_ មីនា

៤_ មេសា ៥_ ឧសភា ៦_ មិថុនា

៧_ កក្កដា ៨_ សីហា ៩_ កញ្ញា

១០_ តុលា ១១_ វិច្ឆិកា ១២_ ធ្នូ ។

# ឆ្នាំទាំង១២



| | | | | |
|---|---|---|---|---|
| ក<br>KOR | ខ<br>KHOR | គ<br>KOA | ឃ<br>KHOA | ង<br>NGOA |
| ច<br>CHOR | ឆ<br>CHHOR | ជ<br>CHOA | ឈ<br>CHHOA | ញ<br>NHOA |
| ដ<br>DOR | ឋ<br>THOR | ឌ<br>DOA | ឍ<br>THOA | ណ<br>NOR |
| ត<br>TOR | ថ<br>THOR | ទ<br>TOA | ធ<br>THOA | ន<br>NOA |
| ប<br>BOR | ផ<br>PHOR | ព<br>POA | ភ<br>PHOA | ម<br>MOA |
| យ<br>YOA | រ<br>ROA | ល<br>LOA | វ<br>VOA | ស<br>SOR |
| ហ<br>HOR | ឡ<br>LOR | អ<br>OR | ។ | |

| | | | | |
|---|---|---|---|---|
| ក | ខ | គ | ឃ | ង |
| カ | ッカ | コ | ッコー | ンゴー |
| ច | ឆ | ជ | ឈ | ញ |
| チャ | チャー | チョー | チヨー | ニョー |
| ដ | ឋ | ឌ | ឍ | ណ |
| ダァ | ター | ドォ | トッー | ノォー |
| ត | ថ | ទ | ធ | ន |
| タァ | ター | トォ | トー | ノゥー |
| ប | ផ | ព | ភ | ម |
| バァ | パー | ポォ | ポー | モゥー |
| យ | រ | ល | វ | ស |
| ヨー | ロ (まきした) | ロー | ヴォ | サァー |
| ហ | ឡ | អ | ៗ | |
| ハァ | ラァ | ア | | |